# ការសំភាសន៍ជាលើកទី២ របស់អ្នកមីងជីម ស្រីពៅ

**ក៖ អ្នកសំភាសន៍ឈ្មោះ រិទ្ធ ស៊ុនភានិច      ខ៖ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ ជីម ស្រីពៅ**

## ការសង្ខេបរបស់អ្នកមីងជីម ស្រីពៅ

អ្នកមីងជីម ស្រីពៅគាត់បានប្រាប់ពីជីវិតរបស់គាត់ជាលើកទី២ហើយគាត់មានការលំបាកជា មួយប្តីគាត់ដោយសារប្តីគាត់ផឹកស្រាមានស្រីហើយធ្វើអោយគាត់មិនសប្បាយចិត្តហើយគាត់បាននិយាយប្រាប់ពីការសុបិន្តរបស់គាត់ថាមានព្រលឹងវិញ្ញាណចង់អោយគាត់ជួយដើម្បីពួក គេអាចស្គាល់ពីព្រះហើយគាត់ពិតជាចង់ជួយតែមិនដឹងធ្វើយ៉ាងម៉េចដើម្បីកាត់អាចជួយដល់គេបាន។ភាគច្រើននៅក្នុងសង្គមនៃប្រជាជនខ្មែរគឺភាគច្រើនជឿទៅលើការយល់សប្តិ។

ក៖ ចឹងថ្ងៃនេះញ៉ុមសូមអរគុណដែលបានផ្តល់ពេលវេលាដើម្បីញ៉ុមអាចចាប់ផ្តើមការសំភាសន៍ ជាថ្មីម្តងទៀតហើយថ្ងៃនេះគឺសំភាសន៍នៅថ្ងៃទី០៣ ខែ០៧ ឆ្នាំ២០១៧ហើយសំភាសន៍ដោយ ខ្ញុំផ្ទាល់ រិទ្ធ ស៊ុនភានិច មីងអាចជំរាបឈ្មោះពេញបានទេ?

ខ៖ ញ៉ុមឈ្មោះ ជីម ស្រីពៅ។

ក៖ អ្នកមីងពៅ។ចាំចឹងអ្នកមីងអាចរៀបរាប់ពីខ្សែជីវិតរបស់អ្នកមីងពីក្មេងរហូតមកដល់ពេលនេះបានទេ?

ខ៖ បានតែបានខ្លះៗ។

ក៖ ចាំ!

ខ៖ ខ្លាចវាមានភាពចងចាំអត់បានច្រើនទេ។

ក៖ ចឹងញ៉ុមជួយរំលឹក អូខេ!

ខ៖ និយាយទៅដកដង្ហើមធំ។តូចៗហ្នឹងពិបាកណាស់! យើងមិនមានបានហូបគ្រប់គ្រាន់ព្រោះអីយើងគ្មានឪពុកម៉ែគាត់រកតែឯងហើយយាយចាស់មួយតែឥឡូវគាត់ស្លាប់បាត់ហើយគាត់អាយុជំនាលសម្តេចតា។

ក៖ គាត់ជាយាយរបស់មីងហេ?

ខ៖ យាយញ៉ុមដែរប៉ុន្តែគាត់ខាងប៉ាញ៉ុមម្តាយខាងប៉ាហើយយាយញ៉ុមស្រលាញ់ខ្ញុំផ្តាំហើយគាត់ស្រលាញ់ហើយពាក្យថាស្រលាញ់អត់អោយថៅដឹងចិត្ត។

ក៖ ស្រលាញ់លាក់។

ខ៖ ហើយគាត់សុខចិត្តមានអង្ករមានអីអញ្ចេះម៉ែញ៉ុមទៅរកបានអង្ករបានអីមក គាត់សុខចិត្តអោយថៅៗហូបគាត់សុខចិត្តអង្គុយហូប ដល់នៅសល់បានគាត់ហូបបើអត់សល់ គាត់អត់ ប៉ុន្តែដល់តែយើងកាលណោះយើងចាំមើលគាត់ដែរចាំមើលហៅគាត់ហូបដែរគាត់អត់រវល់គាត់ថាគាត់ហូបបាយកកហូបអី យើងទូចៗយើងម៉េចដឹង។

ក៖ ចាំ!

ខ៖ ដឹងថាគាត់ហូបមិនហូបគា ត់ថាហូបក៏ហូបហ្នឹងឯងគាត់ថាអត់ក៏អត់ហ្នឹងហាំ!

ក៖ គាត់ឈ្មោះអីដែរមីង?

ខ៖ ឈ្មោះយាយយុត។

ក៖ ចាំ!

ខ៖ ប៉ុន្តែគាត់ស្លាប់ហើយ គាត់មិនដូចតាញ៉ុមទេគាត់ស្លាប់មុនទៅ ទៀត យាយញ៉ុមគាត់ស្លាប់ស្រួលទៅ ស្លាប់ដោយមិនពិបាក ដូចដេកលក់ចឹងឯងគ្រាន់តែគាត់ ដកចង្ការមាត់៣ដងក៏ផុតទៅដូចដេកលក់ គាត់អត់មានពិបាកអន្ទាស់អន្ទែង គាត់ទៅដោយ ស្រួល ហើយម៉ែញ៉ុមវិញហ្មំគាត់លំបាកវេទនាជួនកាលយប់ឡើងគេជួលគាត់អោយបុកស្រូវបុ កអង្ករគាត់ឈ្នួលបុកអោយគេទៅយប់ទៅ ពេលមុនដំបូងយើងដេក ដេកស្តាប់គាត់បុកទៅថា ថ្លង់ទៅពេលយូរៗទៅវាស៊ាំមពិរោះដេកលក់ទៅ ថ្ងៃណាក៏ជួយ ជួយកំដរគាត់ទៅថ្ងៃណាទៅក៏ អត់និយាយពីប្រវត្តិពីដើមទៅអាយើងហើយអ្នកខ្លះគេមានបាយហូបពេញៗមាត់យើងអត់ជួនកាលយើងមានអង្ករតែ

មួយកំប៉ុងទៅកាប់ផាងត្រាវបបរ បបរផេក គេហៅថាបបរផេកម៉ែគាត់ កាត់គល់ស្លឹកគ្រៃក៏បុក មកក៏ស្លអោយកូនចៅទៅបបរលាយនេះហ្នឹងឯងអោយហូបទៅ បើបង ញ៉ុមអត់ហូបទេ ពេលខ្លះណាអង្គុយយំ គាត់អត់ហូបទេគាត់អង្គុយយំ ហើយមានលុយកាក់ឯ ណាទៅរៀនទៅសូត្រកាលហ្នឹងមានថាទៅរៀនអត់លុយឯណា ទៅរៀនសុទ្ធតែបង់សាលា ១៥០០ យើងទៅរកលុយឯណាលុយ១៥០០ ១៥០០កាលណោះថ្លៃណាស់! ១កាក់២កាក់១ សេន ២សេនហ្នឹង។

ក៖ ចាំ!

ខ៖ អោយតែបានលុយ១សេន ២សេនទិញនំទិញអីនោះហ៊ូសប្បា យចិត្តបើម៉ែយើងរកមិនបានដែរខំប្រឹងព្រោះគាត់អត់ចេះជិះកង់គាត់ក៏ដកព្រលិតបេះបន្លែក្រោ យផ្ទះហ្នឹងពួកញ៉ុមទៅជួយគាត់ឡើងបេះត្របែក បេះអំពិល ដកព្រលិតពេលព្រឹកព្រលឹមឡើង ម៉ោង៤ឡើងគាត់យកទៅលក់ យកទៅលក់ទៅមកវិញក៏បានត្រីខ្លះទៅបានអង្ករខ្លះទៅទីញ មកវិញគាត់ត្រូវការទៅដកទៅស្ទូងអោយគេទៀត គេជួលស្ទូងគេចុះយើងមានស្រែមានស្រូវឯ ណាច្រូតច្រើនដូចគេយើងមានតែមួយហិចតាទៅ ធ្វើម៉ាហូបហ្នឹងឯងជួយអ៊ំផង ជួយអ៊ំមិនដៃ លបានអីទេប្រវត្តិវេទនាគ្មានអ្នកណាវេទនាដូចម៉ែញ៉ុមទេមានកូនចៅវេទនាណាស់! អាឈ្មុះតែ យំទេ យើងយំទឹកភ្នែក កាលយើងចូលម៉ែញ៉ុមវេទនា យូនធ្វើបាបម៉ែញ៉ុមចាំធ្វើបាបម៉ែញ៉ុមថា ម៉ែញ៉ុមលាក់មនុស្ស លាក់អ្នកណាគេទេម៉ែញ៉ុមនោះគាត់មានលាក់ឯណាំហើយគាត់អោយ ទៅដកខ្ទឹមក្រហមអោយ ម៉ែញ៉ុមថាអោយទៅដកខ្លួនឯងគាត់ថាឪដាក់គាត់ ឪដាក់វាហើយវា ស្រលាញ់បងញ៉ុម ស្រលាញ់បងញ៉ុមទៅ អាខ្លះក៏ជួយម៉ែញ៉ុមខ្លះទៅអត់ បានតែឆាសកឆាស ចឹងនិយាយទៅចូលចំណុចចង់ ហើយមិនមានអីច្រើនទេញ៉ុម ញ៉ុមមានតែប៉ុណ្ណឹងឯង និយា យច្រើនទឹកភ្នែកទឹកសំបោរ ចង់តែមានចង់តែផ្តាំផ្ញើរអោយកូនចៅអោយមានភាពតស៊ូ ហើយ ក៏ចង់អោយវាមានភាពចេះដឹងរកការងារធ្វើដើម្បីចិញ្ចឹមជីវិត ជីវិតខ្លួនវាព្រោះយើងគ្មានអីអោ យវាទេហើយកុំឃើញគេមានហ៊ូអានេះ រកស៊ីមានអញទៅលួចទៅឆក់ប្លន់អានោះគុកលឿនណាស់ចង់អោយតែមានភាពអង់អាចដោយខ្លួនឯងប្រឹងរកស៊ីដោយខ្លួនឯងកុំអោយហើយដឹងតែគេមានយើងត្រូវតែប្រឹងរកស៊ីតែខ្លួនឯង ដើម្បីអោយមានជាងគេ កុំយកដែលភាពដែលមានគេ យើងម៉េចក៏អត់បើយើងមិនប្រឹងយើងធ្វើម៉េចបានអោយយើងចេះប្រឹងចេះតស៊ូខ្លួនយើងម៉ែឪគ្មានអីចែកទេ បើម៉ែឪក្រដែរ មកពីយាយពីតាមកពីអត់ហ្នឹងហើយមានតែខ្លួនមានតែប្រាណមកចង់អោយវារៀនចង់អោយវាមានភាពរឹងពឹងហើយអោយវាចេះតស៊ូខ្លួនឯង ។

កៈ ចាំចឹងអ្វីដែលអ្នកមីងនិយាយពីមុនគឺពាក់ពន្ធ័ទៅនឹងជីវិតរបស់អ្នកមីងពីក្មេងមែនទេអ្នកមីង! ចុះសំរាប់អាពាហ៍ពិពាហ៍មីង មីងជួបរឿងរ៉ាវអីគេខ្លះទុក្ខលំបាកអ្វីខ្លះ ភាពសប្បាយអ្វីខ្លះចឹងហាំ?

ខៈ វាពិបាកណាស់!

កៈ រំលឹកអនុស្សាវរីយ៍ចាស់ចឹងហាំ!

ខៈ នឹកអោយគាត់ នឹកយ៉ាងណាក៏គាត់នៅតែហិសហិស! ដាក់យើងវាពិបាក ពីមុនយើងបានគ្នាមកក៏យើងអត់មានអីទេមានតែកង់កញ្ចាស់ហ្នឹងឯងឌុបគ្នាពីជំដែកមកសៀម រាបនេះទៅធ្វើការសំនង់ អាហ្នឹងមានអនុស្សាវរីយ៍មួយ ថ្ងៃនោះអនុស្សាវរីយ៍កាលណោះមក ។

កៈ ពីរនាក់ប្ដីប្រពន្ធ។

ខៈ ពីរនាក់ប្តីប្រពន្ធ កូនមួយ កាលហ្នឹងយើងមានកូនមួយទៅដល់ពេលមករកស៊ី ដល់ពេលរកស៊ីក៏ខ្វះទៀត អាប្តីទៅចូកខ្សាច់ដាក់ឡានគេក៏បាន៥០០០ ១០០០០អើបើគាត់ថ្ងៃណាអត់បានទៅក៏អត់បើបងនៅផ្ទះបងវិញបងក៏គាត់ក្រ ប៉ុនការសប្បាយ ការសប្បាយមានទុកខ្លះដែរ ដល់ពេលចូលមកក្រោយៗទៀតបាន២០០៣ ២០០៤ បានអាណោះបានវេទនាពេញអនុស្សាវរីយ៍មិនមែនអនុស្សាវរីយ៍ជាមួយញ៉ុមទេណាស់ អនុស្សាវរីយ៍ជាមួយគេ រហូតដល់២០០៥ទៀត ២០០៥ មានតែទៅដេកហ្នឹងគេមួយយប់បាត់មួយយប់ក៏ព្រឹកឡើងបានមកវិញ មានអាសុំញ៉ុមយកប្រពន្ធមួយទៀត គេមាន គេមានគេសុំញ៉ុមថាយកមួយទៀតទៅដើម្បីមកចិញ្ចឹមពួកញ៉ុម ញ៉ុមថាអើស្រីដូចគ្នាញ៉ុមអត់ទេបើមានគេគឺអត់ញ៉ុមហើយមានញ៉ុមអត់គេហើយត្រូវមីនោះហើយត្រូវស្រី ណោះគេ គេថាមានប្រពន្ធហើយគេនៅមកចង់មើលមុខប្រពន្ធទៀតមានប្រពន្ធក៏គេ នៅតែយក មានប្រពន្ធនៅតែយក ហើយញ៉ុមថាធ្វើបាបស្រីដូចគ្នាបើចង់បានក៏យកទៅញ៉ុមអ ត់មាននេះទេ ហើយរហូតមកដល់ឥលូវក៏ដូចតែគ្នា ចូលនៅក្នុងសាសនាចក្រហើយក៏នៅតែ មានបំនងហើយគាត់ខូចត្រង់នេះគាត់ថាគាត់សព្វថ្ងៃគាត់អត់មានចង់បានលោភលន់អីទេ ញ៉ុ មថាម៉េចអត់ចង់បានលោភលន់អី ទ្រព្យសម្បត្តិគាត់ក៏អត់ចង់បានស្អីក៏គាត់អត់ចង់បានតែគាត់ មានតែចិត្តតូចមួយ តូចមួយ ហើយញ៉ុមថាចិត្តតូចមួយហ្នឹងស្អីគេ ចិត្តតូចមួយគាត់ថានៅតែប្រ ព្រឹត្តរឿងស្រា មួយទៀតគឺស្រី ញ៉ុមថាបាន យកបានតើ កាល២០០៧ហ្នឹងស្រលាញ់មេម៉ាយ ស្រលាញ់មេម៉ាយមួយ ស្រលាញ់មេម៉ាយទៅអោយតែញ៉ុមនេះអ្នកធ្វើមេអណ្តើក មេកន្តាយញ៉ុ មថាហ៊ី មេអណ្តើកមេកន្តាយម៉េចរួចទេ អាមេអណ្តើកមេកន្តាយញ៉ុមធ្លាប់ធ្វើហើយ

កាលពេល ញ៉ុមពីនៅលីវ គេចង់ស្ទោរម្តងហើយ មែនធ្វើអោយមីប្អូនខាងផ្លូវនាគកូនតាម មីនោះវាជំនាល ញ៉ុមប៉ុន្តែវាប្អូនខែ គេស្រលាញ់ទៅវិញទៅមក ទៅវិញទៅមក ដល់ម៉េចក៏ថ្ងៃនោះឯងគេអោយ ញ៉ុមឆ្លើយឆ្លងគ្នា ខាងណោះគេប្រាប់មកញ៉ុម អោយញ៉ុមទៅប្រាប់ឯណោះប្រាប់ណោះប្រាប់ ណោះអាមេអណ្តើកមេកន្ដាយនេះនិយាយចុះនិយាយឡើងគេថាមានខាងណោះគេនិយាយទេមានតែញ៉ុមអ្នកនិយាយ ទេអញអត់បានដឹងរឿងអីទេ ទេអញទៅផ្ទះអញហើយ។

ក៖ ចេះធ្វើមេអណ្តើកអីណា!

ខ៖ គេចង់ចាប់អណ្តើកស្ទោរគេថាចាប់ខុសៗហើរ! មិនបានទេរួចខ្លួនហើយហើយយើងវាឆោតដែរយើងមិនបាននេះ កាលណោះបើសិនជាយើងដឹងមិនដូចសម័យនេះគ្រាន់តែអោបគ្រាន់តែថើបគ្នាវាមិនផើមអត់ដែលទាន់យកប្តីទេ។

ក៖ ទៅចឹងទៅ។

ខ៖ អាក្រលងជើងនេះមួយទឹមដឹង ដឹងអា២០០១ ២០០២ នេះទេក្រមុំមិនដឹងទេ អាយើងមកវាឯណេះទៅដឹង អាម៉ែញ៉ុមចាស់ៗគាត់ប្រសប់កុហកដែរ ឯងវាមិនដឹងដែរ ហ៊ានតែអាណាក្រលងជើងមិនបានទេ មានតែឃើញក្រលងអីដកជើងអោយលឿន ផើមអញអំពុលទុកបណ្តោយអត់ដឹងអាគេចាប់ដៃអោបថើបនេះផើមដៃរភ័យខ្លួនថាផើមហើយពេលនេះដឹងតែផើមហើយចុះវាអត់ដឹងហ្ន៎! អាណាចាប់អញថើបចាប់អោបអញ អញយកហើយ បើដឹងអត់យក បើដឹងប៉ុននេះនៅសប្បាយនឹងគេបាត់។

ក៖ ហ៊ីកូនឡើងកគោកហើយ!

ខ៖ អានោះបានថាមកពីយើងអត់ដឹង អាទុក្ខលាយសប្បាយ។

ក៖ ចា៎!

ខ៖ ថ្ងៃក៏មានប្តីក៏មានអីបា ក់ទឹកចិត្តក៏នៅតែមានអារម្មណ៍អញ្ចេះទៀត អត់ចង់ជួបទុក្ខទេមែនវាឆ្អែតឆ្អន់ហើយ មានតែ ប៉ុណ្ណឹងឯងផ្តាំផ្ញើរកូនចៅមានមួយស្មោះមួយទៅកុំអោយមានមួយហើយស្មោះ២ ៣ប្រយត្ន័ពិ បាកចងករកើតអេដស៍។

កៈ ឥឡូវញ៉ុមចង់អោយមីងនិយាយពីកន្លែងដែលថាមីងអត់ដឹងហាំ អត់ដឹងពីចំនុចមួយហ្នឹងហាំដល់ពេលអ្នកមីងនិយាយបែបហ្នឹងកូនស្រីអ្នកមីងកូនប្រុសអ្នកមីង តែកូនស្រីសំខាន់ជាង !

ខៈ និយាយថាម៉េចទៀត?

កៈ ថាដូចអ្នកមីងថាក្រលងជើងម៉េចហ្នំ?

ខៈ ហ្នំអត់ដឹង គ្រាន់ថាចាស់ៗពីដើមកុហាកយើង កុហាកយើងថាអោយតែប្រុសៗចាប់ចើបឬក៏អោបអីដឹងតែថាផើមវាអត់ដឹង គ្រាន់តែថាវាមិនមែនអញ្ចុះទេ គ្រាន់តែចើបគ្រាន់តែអោបវាមិនអស់លុយទេ កុំឆោតថ្ងៃក្រោយគ្រាន់តែប៉ុណ្ណោះទេ!

កៈ សព្វថ្ងៃមីងមានគោលដៅជីវិតខ្លួនឯងអត់?

ខៈ គោលដៅជីវិតម៉េច?

កៈ ដូចថាគោលដៅដូចជារៀបផែនការពេលថ្ងៃអនាគតសំរាប់កូនៗអីចឹងហាំ!

ខៈ ហ្នំ ចង់ថាអញ្ចេកចង់ថាអើដល់នេះញ៉ុមរឹងដៃរឹងជើងនេះចង់រកស៊ីដើម្បីអោយកូនបានជ្រៅជ្រះដើម្បីវាយកភាពដែលវាចេះហ្នឹង ទៅធ្វើការធ្វើងារបានប្រលងទៅបានធ្វើការធ្វើងារដើម្បីចិញ្ចឹមជីវិតខ្លួនវាហើយម៉ែឪគ្មានអីទេមានតែការជំរុញកូនអោយរៀនអោយចេះដឹងមានការងារធ្វើបើវាថារៀនអត់កើតក៏មានតែកន្លែងគេបង្រៀនអត់យកលុយយើងយកវាទៅដាក់ខាងជំនាញអីមួយទៅវាចង់ពេលយើងចេញមកគេរកការងារអោយធ្វើ។

កៈ ចាំ!

ខៈ ហើយអោយវាសំរេច ចិត្តខ្លួនវាសិន។

កៈ ចុះសព្វថ្ងៃមីងធ្វើអីគេដែរ?

ខៈ ញ៉ុមអត់ទាន់បានធ្វើអីទេតែប្ដីធ្វើការសំនង់។

កៈ ឥឡូវមីងមានសមាជិកមួយទៀតហើយហោ?

ខៈ សមាជិក។

ក៖ គាត់កូនស្រីមីងហេ៎?

ខ៖ កូនស្រី!

ក៖ ហើយដាក់ឈ្មោះអោយគាត់នៅ?

ខ៖ ដាក់រួចហើយប៉ាគេដាក់ឈ្មោះ។

ក៖ ឈ្មោះអី?

ខ៖ ដាក់ រី សារ៉ាវាយណ៍។អាឈ្មោះហ្នឹងអែលឌើរអ្នកដាក់។

ក៖ រី សារ៉ាវាយណ៍។

ខ៖ វាយណ៍ៗហ្នឹងអែលឌើរអ្នកដាក់ហើយវ៉ាៗនេះយកឈ្មោះបងវា ប្ដីញ៉ុមមុនដំបូងគាត់ដាក់ឈ្មោះអោយអើអាម៉ីម៉ីទេ ដល់ពេលអែលឌើរថាមានព្រះគម្ពីរ ក្នុងព្រះគម្ពីរហ្នឹងមានមានឈ្មោះចឹងឯង។

ក៖ សារ៉ាយណ៍!

ខ៖ ទៅគាត់អោយដាក់ចឹងទៅ ដាក់តាមអែលឌើរហ្នឹង ហេគេថាខ្មៅឈ្មោះឡូយម្ល៉េះ។

ក៖ ចាំមើលតែគេធំឡើងសរហា៎!

ខ៖ ខ្មៅមែន ខ្មៅ៣នាក់កូន។

ក៖ ហ្ន៎មីងកើតគាត់បានប៉ុន្មានខែហើយ?

ខ៖ បានជិតមួយខែកន្លះខ្វះអើ៧ថ្ងៃទៀត។

ក៖ ហ៊ីខ្វះមួយអាទិត្យទៀត ។ចឹងអ្នកមីងសំរាប់ចូលចិត្តជាពណ៌វិញតើមីងចូលចិត្តប្រភេទជាពណ៌អីដែរសំរាប់ជាសំលៀកបំពាក់សំរាប់អីចឹងហា៎?

ខ៖ ពណ៌ផ្កាឈូក ។

ក៖ ចឹងបានពាក់ពណ៌ផ្កាឈូក។ហេតុអីបានមីងចូលចិត្តពណ៌ហ្នឹង?

ខ៖ ពណ៌ហ្នឹងមើលទៅដូចស្រស់ វាស្រស់ៗហើយតែយើងទៅណាចូលចំណោមគេក៏វាចុះៗ

ក៖ ហើយចុះសំរាប់កូនៗមីងមានអ្នកណាគេចូលចិត្តពណ៌ហ្នឹងទេ?

ខ៖ អត់ដឹងថាវាចូលចិត្តពណ៌អីទេព្រោះមិនដែលបានសួរ ហើយសូម្បីតែខោលីអូវវាក៏ញ៉ុម ទិញ ពណ៌ផ្កាឈូកអោយដែរៗ

ក៖ ចុះស្វាមីមីងវិញ?

ខ៖ មិនដឹងថាគាត់ចូលចិត្តពណ៌អីបើស្រីគាត់ចូលចិត្តតែបប្ធូរមាត់ក្រហមៗ

ក៖ ចុះសំរាប់ដូចជាប្រភេទសត្វវិញតើមីងចូលចិត្តសត្វប្រភេទអីគេ?

ខ៖ សំរាប់សត្វវិញអត់មានអីដែលចូលចិត្តសត្វដែលខុសពីស្លូតៗ អត់សូវចូលចិត្តទេ ចូលចិត្តតែកាចៗខ្លា ព្រោះយើងមែនញ៉ុមនិយាយមិនកុហកទេញ៉ុមនឹកឃើញថាពេលញ៉ុមមានភាពស្លូតពេកប្តីឯងធ្វើបាបបើញ៉ុមយកភាពកាចមកដាក់គ្រាន់ អានេះគេថាកុំឃើញថាខ្លាស្លូតថាខ្លាដេកៗ

ក៖ ខ្លាដេកលក់ៗ

ខ៖ ញ៉ុមចូលចិត្តអាសត្វខ្លាហ្នឹងឯងព្រោះអីមើលចង្កូមវាទៅគួរអោយហ៊ីតែមួយម៉ាតមកគឺវាចប់ពេលប្តីញ៉ុមក៏ដោយ ប្តីញ៉ុមអោយតែឃើញញ៉ុមខឹងហើយគាត់អត់ដែលនេះទេគាត់ដើរគេចបើញ៉ុមចាប់អីត្រូវដាក់ញ៉ុមក៏ដាក់ដែរៗ

ក៖ គាត់ស្លូតបូតហ៎អ្នកមីង?

ខ៖ គាត់ស្លូត គាត់មិនស្លូតទេគាត់ដូចថាគាត់ធ្វើខុសគាត់ស្លូតទេបើថាគាត់អត់ធ្វើខុសទេគាត់និយាយប្រាប់យើងតែមួយម៉ាត់ៗ គាត់ដឹងថាគាត់ធ្វើខុសៗ

ក៖ ចឹងសុំទោសមីងសូមសួរមួយគាត់ដែលរករឿងក្នុងផ្ទះអីខ្លាំងៗទេ?

ខ៖ អត់ទេៗ

ក៖ ចឹងក្នុងផ្ទះទាំង២នាក់ហ្នឹងអ្នកណាកាចជាង?

ខ៖ ហ្នុំខ្លានេះហើយកាចជាងមែន!

ក៖ កាចម្ល៉េះមីង?

ខ៖ និយាយតាមត្រង់គាត់អត់ដែលរករឿងញ៉ុមទេ គាត់រករឿងញ៉ុមម្តងគាត់រករឿងអានោះនោះ ដូចគាត់ថាតែស្រលាញ់គឺចេះប្រចណ្ឌហើយញ៉ុមលើកនោះ មកពីគាត់ច្រលំលេខទេមកពីកំពត ដល់មកពីកំពតទៅគាត់តេទៅគាត់សុំនិយាយលេងចុះនិយាយលេងឡើងទៅញ៉ុមនេះបង ប្អូនគាត់តេទៅ គាត់ថាហុឺសុំធ្វើបងប្អូនធម៌ ហើយប្តីញ៉ុម ប្តីញ៉ុមគាត់ថាអត់អោយធ្វើទេ បងធម៌ ប្អូនធម៌គាត់ថារឯងជជែកលេងអីមក គាត់ថាពេលគាត់មកអោយគាត់ចង់ចូលលេងនេះឯង ហើយប្តីញ៉ុមអត់អោយទេ អត់អោយចូលលេង អត់អោយញ៉ុមសេពគប់ អោយញ៉ុមលុបលេខ ហ្នឹងឯង ប៉ុន្តែញ៉ុមអត់បានលុបលេខហើយបើលុបលេខខាងយើងឯណេះខាងគេនោះវានៅ មានអោយប្តូរស៊ីម តែញ៉ុមអត់ប្តូរទៅគាត់ឈ្លោះថាញ៉ុមនេះមានគាត់ហើយចង់មានម៉េចទៀត ទៅក៏ញ៉ុមថាហុឺគ្រាន់តែគេសុំរាប់ក៏មិនបានដែរថាអត់អោយរាប់ទេ គាត់អត់អោយរាប់ទេ ទៅក៏ ញ៉ុមតាំងពីនោះឯង មកក៏ឈប់ទៅ ។

ក៖ តែអត់មានការបង្កអីខ្លាំងក្លាឯណាអី?

ខ៖ ទេអត់មានដែរ មានតែញ៉ុមទេខ្លាំង ។

ក៖ ខ្សោយសោះមីង!

ខ៖ ខ្សោយឯណាបើខ្សោយគេសង្រ្គប់យើងបានហើយ យើងត្រូវតែអញ្ចេះឯង គាត់ដែលមានតែម្តងប៉ុណ្ណោះឯងបើថាភាពដែលគាត់ខឹងកូនធ្វើខុសគាត់វ៉ៃកូនមិនមានទេ។

ក៖ វ៉ៃកូនល្អ។

ខ៖ ប៉ុន្តែវ៉ៃកូននោះមិនទាន់ បែកឈាមឡើយ រំពាត់ប៉ុននេះឯណា អាដើមរពាក់យើងនោះដាក់មកមិនបែកប៉ុន្តែតែវ៉ៃកូនរួចអង្គុយស្រក់ទឹកភ្នែកខ្លួនឯង។

ក៖ ហុឺ អានិតកូន។

ខ៖ អានិតកូន។

ក៖ គាត់ចង់អោយកូនល្អ។

ខ៖ គាត់ណៃនាំកូនមួយដង ពីរដងឡើងបីដងដាក់បណ្តោយ ទាំង២មានស្លាកស្នាមទាំង២ ប្រុសៗ។

ក៖ មួយណាដែរមីង។

ខ៖ អាស្វុន អាស្វ៉ាន់ ២ នាក់ហ្នឹងដាក់គ្នា។

ក៖ ចុះសព្វថ្ងៃគាត់កាចទេមីង?

ខ៖ ប្តីញុំម?

ក៖ ចាំ!

ខ៖ អត់ទេ។

ក៖ តែឥឡូវគាត់ស្លូតហើយអ្នកមីង។

ខ៖ ស្លូតនៅតែប៉ុណ្ណឹងឯង គាត់អត់ដែលនេះទេ។ញុំមថាអីញញឹមដាក់មុខ គាត់មានតែភាព២ យ៉ាងហ្នឹងឯងដែលគាត់ជំរុសមិនទាន់បាន តែញុំមថាជ្រមុជទឹកមិនទាន់បានទៀត ខ្លួនឯងផឹក គាត់អធិស្ឋានហើយពេលគាត់ផឹកគាត់អត់បានអធិស្ឋានទេ បើគាត់អត់ផឹកអញ្ចេះគាត់បានអធិ ស្ឋានទៅរកសុំអភ័យទោសពីព្រះ ញុំមថានៅតែចឹងតើបានទេខ្លាំងជាងគេគឺភាពម្យ៉ាងហ្នឹងឯង បំបាត់មិនបានសោះញុំមថាជំរុញព្រះអង្គបានមិនបានអត់ចុះតែទៅព្រះវិហារអោយបានជាប់ គាត់ថាបំភ្លេចណាស់នឹកណាស់ បំភ្លេចណាស់នឹកណាស់។

ក៖ ចុះមីងមានវិធីផ្សេងដែលជួយគាត់បានទេ?

ខ៖ ញុំមមិនដឹងជួយគាត់ម៉េចទៀត មិនដឹងជួយគាត់ម៉េចអោយគាត់ អាភាពហ្នឹងមិនដឹងជួយ គា ត់ម៉េច មានតែប្រាប់គាត់អោយអានព្រះគម្ពីរ ពេលគាត់នឹកឃើញអោយអានព្រះគម្ពីរទៅ ថា អានព្រះគម្ពីរហើយតែឃើញមុខគេនៅក្នុងក្រដាសហ្នឹងឯងញុំមថាចប់ហើយចឹង រកវិធីណា ដែ លរំដោះគាត់បាន រំដោះគាត់មិនបានទេ ឃើញញុំមថាញុំម យកព្រះគម្ពីរមកអានញយៗ ទៅ ពេលញុំមនៅដេកយល់សប្តិក៏ញុំមនៅមានព្រះគម្ពីរនៅជាមួយដែរ នៅមានព្រះឃើញ លើកមុ នញុំមសួរអែលឌើរម្តង ទៅអែលឌើរដើររកចំលើយញុំមអត់ឃើញទេ រកចំលើយអោយ ញុំមអត់ឃើញទេ ខ្មោចសួរញុំមផ្សព្វផ្សាយហ្នំ ផ្សព្វផ្សាយទៅអោយថាជួយ គេបានគេ គេមក

ព្រះវិហារយើងដែរ រួចញ៉ុមញ៉ុមយល់សប្តិនោះញ៉ុមអត់ដឹងថាញ៉ុមមានភាព យល់សប្តិទេអត់ដឹងសោះអញ្ចេកញ៉ុមចង់ដឹងញ៉ុមចង់រកចំលើយអោយអ៊ែលឌើរជួយរកចំលើ យថាអញ្ចេកញ៉ុមមើលព្រះគម្ពីរអានព្រះគម្ពីរបានអានៗៗទៅដល់ពេលយប់នោះឯង យប់ថ្ងៃ សៅរ៍យប់ថ្ងៃសៅរ៍នោះទៅញ៉ុមអានថ្ងៃឡើងញ៉ុមបាន អានៗដល់ពេលយប់នោះឯងបានអាន តែ១ខគត់ ដល់នោះទៅញ៉ុមដាក់គម្ពីរអែបនៅនឹងខ្លួន ដាក់អ៊ែបក្បាលអញ្ចេកឯងទៅដល់ពេល ញ៉ុមដេកៗទៅដូចយល់សប្តិមួយភ្លឹបទៅអញ្ចេះឯងទៅថានៅកន្លែងផ្ទះនោះ ផ្ទះពេលហ្នឹងមាន តែស្បូវទេបាំងស្បូវជញ្ជាំងក៏ស្បូវ ស្បូវទាំងអស់មុនដំបូងយើងដើរទៅ អត់មានមនុស្សទេបើគេ ធ្វើស្រែធ្វើចំការ ដើរហួសទៅបន្តិចទៅមានគេធ្វើស្រែចំការរួច ដល់រួចញ៉ុមនេះហៅគេថាបងប្អូ នមកខាងណេះញ៉ុមមានរឿងមួយចង់ប្រាប់ទៅក៏គេដាក់ចបដាក់អី ដាក់ខ្សែដាក់អីអស់ទៅគេ មកស្តាប់ញ៉ុមនេះឯងស្តាប់ញ៉ុមថាគ្នាគេប្រហែលជា១០នាក់ទេស្រីប្រុសកូនទូចៗផងទៅក៏គេ សួរថាមានរឿងអី ញ៉ុមថាញ៉ុមចង់អោយគាត់ទៅព្រះវិហារ មកស្តាប់ញ៉ុមអានព្រះគម្ពីរអោយ ស្តាប់ទៅមកញ៉ុមអានអោយស្តាប់ញ៉ុមភ្លេចខដែលញ៉ុមអាន ទៅក៏ញ៉ុមថាសាសនាចក្រនេះល្អណាស់បើបងប្អូនបានទៅនឹងអាចឡើងឋានសួគ៌បាន ចុះបើញ៉ុមឡើងឋានសួគ៌បានចុះបើញ៉ុមអត់បានទៅព្រះវិហារហើយញ៉ុមអត់បានទៅជ្រមុជទឹកជ្រមុជអីអញ្ចេះនេះ ញ៉ុមថា ទៅបានចាំញ៉ុមអោយអ៊ែលឌើរមកបង្រៀន ថាបង្រៀនពួកញ៉ុមម៉េចកើត សួរថាបង្រៀនពួកញ៉ុមម៉េចកើតបើញ៉ុមនៅឯណេះគាត់នៅឯណោះហ្នឹង ហើយញ៉ុមថាអាចមកបានតើ ថាអ៊ែលឌើរទៅដល់ណាក៏គាត់ទៅបានដែរ គាត់ជិះកង់មកដែរ ញ៉ុមអត់ដឹងទេ អត់ដឹងថាខ្មោចពិតប្រាកដមិនដឹងថាខ្មោចអីទេដូចមនុស្សយើងធម្មតាស្លៀកធម្មតាទៅគាត់សួរញ៉ុមថាចុះបើញ៉ុមចង់ឡើងទៅឋានសួគ៌ទៅតាមណា ហ៊ីទៅថា អានព្រះគម្ពីរហើយយើងអធិស្ឋានទៅព្រះវិហារ អោយអ៊ែលឌើរទៅបង្រៀនរាល់អាទិត្យទៅហើយពេលយើងស្លាប់ទៅយើងអាចឡើងទៅឋានសួគ៌បានហើយ ហើយគាត់ថាចុះបើញ៉ុមស្លាប់ហើយក៏ញ៉ុមទៅឡើងអោយញ៉ុមទៅតាមណា? ក៏ញ៉ុម ថាអានោះមនុស្សប្រុសទេ ហើយក៏ញ៉ុមថាស្លាប់ឯណាមនុស្សនៅជ្រោងយើងស្លាប់បានអាច ទៅឋានសួគ៌បាន ញ៉ុមថាអញ្ចេះឯងញ៉ុមថាណែហ៊ីញ៉ុមទៅមិនបានទេញ៉ុមនៅទីនេះឯងញ៉ុម ទៅអត់បានទេក៏ថាម៉េចក៏ទៅអត់បានចឹងទៅព្រះវិហារជាមួយញ៉ុមទៅរៀនពីព្រះបន្ទូលពីព្រះ ថាបើយើងអធិស្ឋានយើងអានព្រះគម្ពីររាល់ថ្ងៃ អធិស្ឋានរាល់ថ្ងៃរាល់ពេល ពេលយើងមានទុក្ខលំបាកហើយយើងទៅព្រះវិហារទៅណែ ទៅហូបនំប៉័ងនឹងទឹកទៅ ថាទៅអត់បានចង់អោយញ៉ុមនេះជួយ ជួយអោយគេ ញ៉ុមទាំងដូចញ៉ុមថាអញ្ជឹងថាចាំមើលញ៉ុមជួយ ញ៉ុមជួយស្រាប់តែញ៉ុមជួយទៅញ៉ុមថាក៏ស្រាប់តែអានបាន១ខ២ទៅស្រាប់ញ៉ុមថាហ៊ីទៅវិញហើយ ញ៉ុមទៅវិញហើយ ញ៉ុមថាហ៊ីទៅវិញឯណាមើលញ៉ុមមើលព្រះគម្ពីរញ៉ុមអានព្រះគម្ពីរទាល់តែបើកសៀវ

ភៅទៅអត់ឃើញមានមនុស្សទេ ឃើញតែផ្ទះ មានតែផ្ទះស្បូវ ហ៊ីហើយទៅឯលឿនម្ល៉េះទៅណាអស់ ខ្មោចភ័យរត់ៗអានព្រះគម្ពីរហ្នឹងភ័យរត់ៗខ្លាំងពេកក៏ប្តីញ៉ុមគាត់ដាក់ជើងត្រូវគាត់ថាញ៉ុមនិយាយស្រែកអឺអឺៗទៅគាត់ដាក់ជើងប៉ះលើជើងញ៉ុមទៅក៏ញ៉ុមភ័យញ័រខ្លួនត្រើតៗ ញ៉ុមថានឹកទៅ ហើយញ៉ុមសួរអ៊ែលឌើរចឹង២ឆ្នាំហើយញ៉ុមសួរអ៊ែលឌើរទៅ អ៊ែលឌើរថា ចឹងទៅចាំញ៉ុមរកព្រះគម្ពីរហើយទៅញ៉ុមសួររកចំលើយញ៉ុមអត់ឃើញក៏មិនដឹងទៅរកចំលើយម៉េចឃើញបើចឹង ។

ក៖ ចាំ!

ខ៖ ហើយញ៉ុមនៅតែភ័យមិនទាន់បាត់ផង អោយតែនឹកឃើញអានោះញ៉ុម ពិបាកចិត្តអាហ្នឹងឯងមិនដឹងជួយគេអាម៉េច បើគេថាគេស្លាប់ហើយបើគេមិនបានទៅឡើងឋាន សួគ៌គេមិនអាចមកព្រះវិហារបានទៀតគាត់អោយយើងជួយ បើញ៉ុមជួយខ្លួនឯងមិនរួចផងហ្នឹ ងនៅតែមានបាប មួយបាបជេរកូនបាបជេរប្តី។

ក៖ រឿងធម្មជាតិ។

ខ៖ បើសិនតែប្តីអត់មានគិតបំណងអានោះហាំញ៉ុមអត់ដែលបន្ទោសប្តីអីសោះ អត់ខឹងប្តីទេដោយសារតែប្តីញ៉ុម។

ក៖ ចាំចឹងទាំងអស់នេះជាការចងចាំរបស់អ្នកមីងមែនទេ?

ខ៖ ចាំ! ញ៉ុមចាំបានប៉ុណ្ណោះឯងញ៉ុមហើយញ៉ុមថាបើញ៉ុមទៅព្រះវិហារញ៉ុមចង់អោយគេទៅជា មួយញ៉ុមហើយគេទៅវាមិនបានទេ មិនដឹងជួយម៉េចបានបើញ៉ុម ញ៉ុមចង់ថារកដំណោះស្រាយ ម៉េចអោយជួយគេ ប៉ុន្តែតាមអ៊ែលឌើរគាត់ថាអញ្ចេកគាត់ថាបានទៅបើយើងបានស្គាល់ឈ្មោះ គេយើងសរសេរអាជីវប្រវត្តិដើមដាក់ក្នុងទៅបើយើងបានទៅព្រះវិហារបរិសុទ្ធថាយើងជួយគេ ទៅតែអត់ស្គាល់ឈ្មោះផង បើវាឆ្ងាយវាមាននៅជិតឯណាអើយនៅភ្នំឯណោះ។

ក៖ ចាចឹងអ្នកមីងមានអីនិយាយអីបន្ថែមអត់?

ខ៖ អត់មានទេរកនឹកវាមិនឃើញទេ និយាយអារឿងនេះក៏ដូចវាមានភាពតែនៅនឹងខ្លួន។

ក៖ ចឹងជាការចងចាំរបស់អ្នកមីងតិចតួចដែលអ្នកមីងចាំបានហើយចឹងញ៉ុមក៏អត់មានអីច្រើនការសំភាសន៍របស់យើងគឺត្រូវបានបញ្ចប់៕